**LOWELL PUBLIC SCHOOLS**

ការិយាល័យកណ្តាល Henry J. Mroz Central

155 Merrimack Street
Lowell, MA 01852

ថ្ងៃទី 16 ខែ វិច្ឆិកា ឆ្នាំ 2020

គោរពជូនគ្រួសារសង្កាត់សាលា Lowell Public Schools ៖

ដោយសារយើងកាន់តែខិតជិតដល់ថ្ងៃនៃការថ្លែងអំណរគុណ ខ្ញុំចង់អរគុណលោកអ្នកម្តងទៀតសម្រាប់ការអត់ធ្មត់ ការបត់បែនតាមកាលៈទេសៈ និងភាពជាដៃគូរបស់លោកអ្នក ហើយក៏សូមផ្តល់ជូនលោកអ្នកនូវបច្ចុប្បន្នភាពមួយទៀតអំពីស្ថានភាពបច្ចុប្បន្នទាក់ទងនឹងពេលណាដែលសិស្សនឹងអាចត្រលប់មកកាន់អគារសាលារៀនរបស់យើងវិញ។

វាគួរឲ្យសោកស្តាយ ដែលថាទិន្នន័យជំងឺ COVID-19 នៅទីនេះក្នុងក្រុង Lowell និងនៅទូទាំងរដ្ឋ Massachusetts បន្តងាកទៅខាងទិសដៅខុសឆ្គង។ កាលពីពាក់កណ្តាលខែ តុលា នៅពេលដែលយើងធ្វើការប្រកាសថា យើងកំពុងផ្លាស់ចេញពីផែនការរៀនសូត្រដើមរបស់យើងទៅកាន់ផែនការដែលយើងកំពុងអនុវត្តបច្ចុប្បន្ន អាត្រាចំនួនករណីឆ្លងជាមធ្យមប្រចាំថ្ងៃរបស់ក្រុង Lowell ក្នុងអ្នកស្រុក 100,000 នាក់គឺ 16.4 និង "អាត្រាធ្វើតេស្តិ៍វិជ្ជមានគិតជាភាគរយ" (ភាគរយនៃការធ្វើតេស្តិ៍ដែលវិជ្ជមាននៅទីនេះក្នុងក្រុង Lowell) គឺ 3.29% ។ មួយខែក្រោយមក ក្រុង Lowell គឺនៅតែត្រូវបានគេចាត់ទុកថាជាសហគមន៍មួយដែលមានហានិភ័យខ្ពស់ដដែល សូម្បីអនុលោមតាមគោលការណ៍ណែនាំដែលបានកែសម្រួលហើយរបស់រដ្ឋ Massachusetts ក៏ដោយ។ ដោយផ្អែកលើតួលេខថ្មីបំផុតនេះ អាត្រាចំនួនករណីជាមធ្យមប្រចាំថ្ងៃបានឡើងដល់ 42.1 ហើយអាត្រានៃការធ្វើតេស្តិ៍វិជ្ជមានគិតជាភាគរយនាពេលនេះក៏មានចំនួនខ្ពស់ជាងមុនដែរ គឺមានចំនួន 6.45% ។

ដោយផ្អែកលើនិន្នាការនៅក្នុងទិន្នន័យសុខភាពនេះ និងការប្រកាន់ខ្ជាប់នូវការប្តេជ្ញាចិត្តរបស់យើងនៅក្នុងការចាត់ទុកសុវត្ថិភាពរបស់សិស្ស បុគ្គលិក និងសហគមន៍ធំជាងនេះរបស់យើងជាអាទិភាពចម្បងនោះ **យើងនឹងបន្តផែនការរៀនសូត្រពីចម្ងាយនាពេលបច្ចុប្បន្នរបស់យើង រហូតដល់យ៉ាងហោចណាស់ថ្ងៃទី 4 ខែ មករា។ មានតែសិស្សនៅក្នុងថ្នាក់អប់រំពិសេសដាច់ដោយឡែកពីគេទេនឹងបន្តការរៀនសូត្រដោយផ្ទាល់។**

សូមដឹងថា សេចក្តីសម្រេចនេះមិនបានធ្វើឡើងដោយមិនបានគិតពិចារណាដោយម៉ត់ចត់នោះទេ។ យើងយល់ដែលថាពេញមួយឆ្នាំនេះមានភាពតានតឹងអារម្មណ៍យ៉ាងណា។ ទោះបីជានៅតែមានពេលគ្រប់គ្រាន់ដែលនៅសល់ក្នុងប្រតិទិន នៅមុនវិស្សមកាលរដូវរងារ ដើម្បីឲ្យទិន្នន័យសុខភាពផ្លាស់ត្រលប់ទៅកាន់ទិសដៅប្រសើរជាងនេះវិញក៏ដោយ បន្ទាប់ពីមានការប្រឹក្សាយោបល់ជាមួយនឹងគណៈកម្មការសុខភាពក្រុង វាទំនងជាថា លទ្ធភាពនៃការផ្លាស់ប្តូរបែបនេះប្រហែលជាមិនអាចកើតឡើងច្រើនជាង។ នៅត្រង់ចំណុចនេះ វាមិនអាចជាការពិតទេ ដែលយើងគិតថាយើងនឹងអាចឲ្យសិស្សកាន់តែច្រើនត្រលប់ទៅកាន់ការរៀនសូត្រដោយផ្ទាល់វិញ នៅមុនថ្ងៃទី 4 ខែ មករា ហើយយើងចង់ផ្តល់ឲ្យលោកអ្នកនូវការជូនដំណឹងជាមុនឲ្យបានច្រើនតាមដែលអាចធ្វើទៅបាន ទាក់ទងទៅនឹងសេចក្តីសម្រេចទាំងនេះ។

យើងនឹងបន្តធ្វើការជាមួយនឹងគណៈកម្មការសុខភាពក្រុង Lowell ដើម្បីត្រួតពិនិត្យមើលនិន្នាការនានានៅក្នុងទិន្នន័យជំងឺ COVID-19 ហើយនឹងផ្តល់ជូនលោកអ្នកនូវបច្ចុប្បន្នភាពណាមួយ  ខណៈពេលយើងកំពុងតាមដានផែនការរៀនសូត្ររបស់យើងដែលកំពុងដំណើរការទៅមុខ។

នៅចន្លោះពេលនេះ  សូមចងចាំថា  ត្រូវបន្តអនុវត្តតាមពិធីសារសុវត្ថិភាព  ដែលជួយកាត់បន្ថយការរាលដាលជំងឺ COVID-19 ដូចជាការរក្សាគម្លាតសង្គម ការពាក់ម៉ាស  និងការមិនជួបជុំគ្នាជាក្រុមធំៗជាដើម។  បើសិនយើងអាចកែប្រែចំនួនអ្នកជំងឺ COVID-19 របស់យើងកាន់តែលឿន  យើងនឹងអាចមានសិស្សកាន់តែច្រើននៅក្នុងអគារសាលារៀនរបស់យើងវិញបានកាន់តែឆាប់រហ័ស។

សូមអរគុណជាថ្មីម្តងទៀតចំពោះការអត់ធ្មត់  ការបត់បែនតាមកាលៈទេសៈ  និង  ភាពជាដៃគូរបស់លោកអ្នកពេញមួយរយៈពេលមិនធ្លាប់កើតមាននេះ។

ដោយក្តីស្មោះស្ម័គ្រ,

បណ្ឌិត Joel D. Boyd

អ្នកទទួលខុសត្រូវសង្កាត់សាលា